# វេទិកាវិស័យឯកជនតាមបណ្ដាខេត្ត

## ការត្រៀមខ្លួនសម្រាប់សមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន
## ឱកាស និងបញ្ហាជុំវិញការធ្វើអាជីវកម្ម


**បទបង្ហាញដោយ**

**ឯកឧត្តម ស៊ុន ចាន់ថុល**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសម្រាប់កម្ពុជា និងជាតំណាងជាតិសហគមន៍សេដ្ឋកិច្ចអាស៊ាន**


**ថ្ងៃទី ២៣ និង ២៤ ខែ កុម្ភៈ ឆ្នាំ២០១៥**

https://www.facebook.com/moc.gov.kh



# មាតិកា

I តើយើងឈរនៅទីណា?

II សារជាគន្លឹះ ស្តីពីសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)

III តើយើងនឹងធ្វើអ្វីទៀតនៅក្រោយឆ្នាំ ២០១៥?

https://www.facebook.com/moc.gov.kh

# សេចក្តីផ្តើម

- បច្ចុប្បន្ននេះគឺជាពេលវេលារបស់អាស៊ាន។ ស្ថិតនៅចំបេះដូងនៃរបៀងអភិវឌ្ឍន៍ជួរមុខរបស់ពិភពលោក អាស៊ានបានប្រុងប្រៀបជាស្រេចដើម្បី "ចាប់យកនូវឱកាសដើម្បីអភិវឌ្ឍ"

- ជាមួយនឹងទីផ្សារមួយ ដែលមានអតិថិជនជាង៦១៧ លាននាក់ និងផលិតផលក្នុងស្រុកសរុបជិត ៣ ពាន់ពាន់លានដុល្លា (US$3 trillion) អាស៊ានកំពុងតែផ្តល់នូវអនាគតមួយដ៏រុងរឿងនិងស្ថិរភាព។ សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) គឺជាមូលដ្ឋានគ្រឹះមួយនៅក្នុងចំណោមមូលដ្ឋានគ្រឹះនានានៃអនាគតនោះ។

- កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ សេវា និងវិនិយោគ គឺកំពុងតែផ្លាស់ប្តូរនូវរូបភាពសេដ្ឋកិច្ច និងធ្វើឲ្យមានលំហូរកាន់តែសេរីនូវទំនិញ សេវា វិនិយោគ និងប្រជាជន នៅទូទាំងតំបន់។

# តើយើងឈរនៅទីណា?



- ផែនការលម្អិតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC Blueprint): ត្រូវបានចុះហត្ថលេខានៅក្នុងឆ្នាំ២០០៧។
- បានកំណត់: AEC "នឹងបង្កើតអាស៊ានទៅជាទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ ជាមួយគោលដៅធ្វើឲ្យអាស៊ានពោរពេញទៅដោយថាមពល និងការប្រកួតប្រជែង"

- សសរស្តម្ភទាំង៤ របស់ AEC
  - ១-ទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ
  - ២-តំបន់ដែលមានសេដ្ឋកិច្ចប្រកួតប្រជែង
  - ៣-ការអភិវឌ្ឍន៍សេដ្ឋកិច្ចដោយសមធម៌
  - ៤-សមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក

# តើយើងឈរនៅទីណា?

## *សសរស្តម្ភទី១ :* ទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ



ចំណុចសំខាន់ៗ ប្រាំ:

1. លំហូរដោយសេរីនូវទំនិញ
2. លំហូរដោយសេរីនូវសេវា
3. លំហូរដោយសេរីនូវវិនិយោគ
4. លំហូរកាន់តែសេរីនូវមូលធន និង
5. លំហូរដោយសេរីនូវពលកម្មជំនាញ

# តើយើងឈរនៅទីណា?





## ភាពជឿនលឿនឆ្ពោះទៅគោលដៅ

- ពន្ធគយទាំងអស់បានកាត់បន្ថយមកនៅជិតសូន្យ។
- កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន បានបង្កើតនូវក្របខណ្ឌច្បាប់ដើម្បីសម្រេចនូវលំហូរដោយសេរីនូវទំនិញនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។
- កិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីសេវាកម្ម បានបន្ធូបន្ថយនូវការរឹតត្បិតលើពាណិជកម្មសេវាឆ្លងកាត់ព្រំដែនយ៉ាងហោចណាស់នៅក្នុង ៨០ អនុវិស័យ។
- កិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន បានធ្វើសេរីភាវូបនីយកម្ម និងការពារនូវសកម្មភាពវិនិយោគឆ្លងកាត់ព្រំដែន និងចាប់យកនូវការអនុវត្តប្រសើរបំផុតរបស់អន្តរជាតិ នៅក្នុងប្រព្រឹត្តកម្មវិនិយោគបរទេស។

https://www.facebook.com/moc.gov.kh

# តើយើងឈរនៅទីណា?



## ភាពជឿនលឿនឆ្ពោះទៅគោលដៅ

- កម្មវិធីសាកល្បងសម្រាប់ប្រព័ន្ធចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញដោយខ្លួនឯងសម្រាប់អ្នកនាំចេញ ត្រូវបានចាប់ផ្តើមអនុវត្ត។
- ប្រទេសសមាជិកកំពុងធ្វើការសាកល្បងការផ្លាស់ប្តូរជាដំបូងនូវទិន្នន័យ និងព័ត៌មានពាណិជ្ជកម្ម តាមរយៈផ្លូវចូលច្រកចេញ-ចូលតែមួយអាស៊ាន (ASEAN Single Window Gateway)។
- ការរៀបចំទទួលស្គាល់ទៅវិញទៅមក (MRAs) លើស្តង់ដាបច្ចេកទេសចំនួន ១៧០ ត្រូវបានធ្វើសុខដុមភាពរួចហើយ។
- ផ្សារហ៊ុនមកពីប្រទេសអាស៊ាន៥ និងវៀតណាម បានសហការដើម្បីបង្កើតផ្សារហ៊ុនអាស៊ាន។
- អាស៊ានបានបញ្ចប់ MRAs ទទួលស្គាល់គុណភាពជំនាញវិជ្ជាជីវៈចំនួន៨ ដើម្បីសម្រួលការបម្លាស់ទីនៃអ្នកជំនាញអាស៊ាននៅក្នុងវិស័យទាំង៨នេះ។

# តើយើងឈរនៅទីណា?

## សសរស្តម្ភទី២: តំបន់ដែលមានសេដ្ឋកិច្ចប្រកួតប្រជែង



### ភាពជឿនលឿនឆ្ពោះទៅគោលដៅ

- សហគមន៍សេដ្ឋកិច្ចអាស៊ានបានរិះរកវិធានការនានាដើម្បីលើកកម្ពស់វប្បធម៌នៃការប្រកួតប្រជែងប្រកបដោយភាពត្រឹមត្រូវ រួមទាំងស្ថាប័ន និង ច្បាប់ ដែលគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង រួមទាំងការការពារអ្នកប្រើប្រាស់ និងការការពារកម្មសិទ្ធិបញ្ញា។
- ប្រទេសសមាជិកអាស៊ានកំពុងពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីដាក់ចេញនូវគោលនយោបាយ និងច្បាប់ប្រកួតប្រជែងនៅឆ្នាំ២០១៥។
- សកម្មភាពផ្សព្វផ្សាយនានាកំពុងត្រូវបានធ្វើដើម្បីអប់រំសាធារណជនទូទៅស្តីពីសារៈសំខាន់នៃគោលនយោបាយប្រកួតប្រជែង។

# តើយើងឈរនៅទីណា?



## ភាពជឿនលឿនឆ្ពោះទៅគោលដៅ

- ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធឡូជិស្ទិកសំខាន់ៗ នៃបណ្តាញផ្លូវហាយវេអាស៊ាន ត្រូវបាន និងកំពុងកសាងដើម្បីតភ្ជាប់ជាមួយនឹងផ្លូវថ្នល់សំខាន់ៗរបស់ប្រទេសសមាជិកអាស៊ាន។
- បណ្តាញខ្សែភ្លើងអាស៊ានតភ្ជាប់ឆ្លងកាត់ព្រំដែនចំនួន៦ (នៃបណ្តាញតភ្ជាប់១៦) ត្រូវបានដាក់ឲ្យដំណើរការ។
- បណ្តាញបំពង់បង្ហូរឧស្ម័នឆ្លងកាត់អាស៊ាន បាននិងកំពុងសាងសង់។
- កិច្ចព្រមព្រៀងនិងពិធីសារនៅក្រោមគោលនយោបាយបើកចំហជើងមេឃអាស៊ាន ត្រូវបានបញ្ចប់ និងអនុវត្ត ដោយប្រទេសសមាជិកអាស៊ានភាគច្រើន។
- អាស៊ានកំពុងបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍។

# តើយើងឈរនៅទីណា?

## សសរស្តម្ភទី៣: ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌



### ភាពជឿនលឿនឆ្ពោះទៅគោលដៅ

- អាស៊ានមានមជ្ឈមណ្ឌលបណ្តុះបណ្តាលអាជីវកម្ម និងគំនិតផ្ទៃប្រឌិតចំនួន ៣០ នៅក្រោមបណ្តាញអ្នកបណ្តុះបណ្តាលអាជីវកម្មអាស៊ាន (ASEAN Business Incubator Network) ដើម្បីជម្រុញការជួបទំនាក់ទំនង និងអភិវឌ្ឍអាជីវកម្ម។
- អាស៊ានបានរៀបចំសៀវភៅមគ្គុទេសក៍សហគ្រាសតូច និងមធ្យម ទាក់ទងនឹងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ ។
- គំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន (IAI) នឹងធ្វើឲ្យសមាជិកអាស៊ានទាំងអស់ទទួលផលប្រយោជន៍ប្រហាក់ប្រហែលគ្នាពីសហគមន៍សេដ្ឋកិច្ចអាស៊ាន។
- ក្របខណ្ឌអាស៊ានសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយសមធម៌ (AFEED) ត្រូវបានដាក់ឲ្យប្រើនៅក្នុងឆ្នាំ២០១១។

# តើយើងឈរនៅទីណា?

## សសរស្តម្ភទី៤: សមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក



### ភាពជឿនលឿនឆ្ពោះទៅគោលដៅ

- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានបូក១ "ASEAN+1 FTAs" ជាមួយសាធារណរដ្ឋប្រជាមានិតចិន ជប៉ុន សាធារណរដ្ឋកូរ៉េ អូស្ត្រាលី ណូវែលហ្សេឡង់ និងសាធារណរដ្ឋឥណ្ឌា បានធ្វើឲ្យតំបន់អាស៊ានទៅជាមជ្ឈមណ្ឌលនៃសង្វាក់ផលិតកម្មពិភពលោក។
- អាស៊ានកំពុងតែចរចាភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) ជាកិច្ចព្រមព្រៀងពាក់ព័ន្ធអាស៊ាន និងដៃគូកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរបស់ខ្លួនទាំង៦។ RCEP មាន GDP សរុបប្រហែល ២១,២ លានលានដុល្លា (US$21.2 trillion) ស្មើ ៣០% នៃ GDP ពិភពលោក និងជាទីផ្សារដែលមានប្រជាជន ៣,៤ ពាន់លាននាក់ (48% នៃចំនួនប្រជាជនពិភពលោក)។

# តើយើងឈរនៅទីណា?

## ការកើនឡើងនូវការចាប់អារម្មណ៍របស់អាជីវករនៅលើ AEC

- ការស្ទង់មតិធ្វើដោយសភាពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកបានបង្ហាញថា ៥៤% នៃក្រុមហ៊ុនអាមេរិក មានយុទ្ធសាស្ត្រធ្វើអាជីវកម្មនៅអាស៊ាន ។
- របាយការណ៍របស់ក្រុមប្រឹក្សាពិគ្រោះយោបល់ពាណិជ្ជកម្មអាស៊ាន (ABAC) បានកត់សម្គាល់ថា នៅក្នុងឆ្នាំ២០១៣ ការស្ទង់មតិរបស់ ABAC អំពីភាពប្រកួតប្រជែង បានបង្ហាញថា ៩៨% នៃអ្នកឆ្លើយតប បាននិយាយថា ពួកគេបានពិចារណាលើភាពទាក់ទាញរបស់តំបន់អាស៊ានទាំងមូល ក្នុងយុទ្ធសាស្ត្រវិនិយោគរបស់ពួកគេក្នុងតំបន់អាស៊ាន។

# ASEAN




**Created 8/8/1967**

**Members:**
**Brunei**
**Cambodia**
**Indonesia**
**Lao PDR**
**Malaysia**
**Myanmar**
**Philippines**
**Singapore**
**Thailand**
**Vietnam**

**Cambodia joined ASEAN 30 April 1999**

STRATEGIC LOCATION
IN SOUTH-EAST ASIA

# KEY ECONOMIC DATA OF ASEAN

| | 1990 | 2000 | 2012 | 2013 |
|---|---|---|---|---|
| Total GDP (US$ Billion) | 334.1 | 606.4 | 2,321.1 | 2,395.3 |
| Avg GDP per capita (US$) | 760.9 | 1,172.4 | 3,748.4 | *3,832* |
| Total Trade (US$ Billion) | 306.4 | 759.1 | 2,476.4 | 2,511.5 |
| Intra-Trade (US$ Billion) | 144.1 | 166.8 | 602.0 | 608.6 |
| FDI Inflows (US$ Billion) | 12.8 | 21.8 | 114.3 | 122.4 |
| FDI Inflows (% of Global Inflows) | 6.2 | 1.6 | 8.2 | n.a |
| Population (Million) | 317.2 | 517.3 | 617.2 | 625.1 |
| Poverty Rate (% Population Living Below US$1.25 per day) | 45.0 | 33.0 | 15.3 | n.a |
| Infant Mortality Rate (per 1,000 live births) | 27.3 | 35.9 | 22.4 | n.a |

# KEY ECONOMIC DATA OF CAMBODIA

| | 2000 | 2012 | 2013 | 2014 |
|---|---|---|---|---|
| **Total GDP (US$ Million)** | 3,649 | 14,036 | 15,191 | n.a |
| **Avg GDP per capita (US$)** | 295 | 971 | 1,043 | 1,130 pj |
| **Total Trade (US$ Million)** | 2,772 | 14,897 | 18, 324 | 19,125 pj |
| **FDI Inflows (US$ Million)** | 218 | 2,277 | 4,483 | 1,610 |
| **Population (Million)** | 13 | 14.3 | 14.7 | 15.1 e |
| **Poverty Rate (% Population Living Below US$1.25/day)** | 37 | 18.6 | n.a | n.a |
| **Infant Mortality Rate (per 1,000 live births)** | 80 | 33.9 | n.a | n.a |

https://www.facebook.com/moc.gov.kh

# CAMBODIA'S TOTAL TRADE WITH ASEAN

**US Dollar Thousand**

| | 2009 | 2010 | 2011 | 2012 | 2013 |
|---|---|---|---|---|---|
| ASEAN | 2,100,044 | 2,387,383 | 3,071,554 | 3,512,332 | 4,125,738 |
| Thailand | 486,968 | 840,810 | 916,947 | 1,004,580 | 1,331,258 |
| Singapore | 691,474 | 585,686 | 679,935 | 943,099 | 1,142,093 |
| Viet Nam | 609,259 | 583,437 | 1,031,746 | 1,053,309 | 1,095,613 |
| Malaysia | 146,224 | 184,976 | 509,892 | 265,260 | 269,997 |
| Indonesia | 149,889 | 179,471 | 175,595 | 223,774 | 258,319 |
| Philippines | 14,255 | 10,010 | 9,565 | 15,755 | 21,373 |
| Laos | 886 | 2382 | 2,159 | 6,330 | 5,950 |
| Myanmar | 100 | 54 | 211 | 197 | 938 |
| Brunei | 989 | 557 | 450 | 28 | 197 |

Source: ITC

# CAMBODIA'S EXPORT TO ASEAN

**US Dollar Thousand**

| | 2009 | 2010 | 2011 | 2012 | 2013 |
|---|---|---|---|---|---|
| Total Export | 645,435 | 703,368 | 835,434 | 1,005,797 | 1,293,453 |
| Singapore | 482,445 | 429,981 | 441,877 | 684,669 | 793,575 |
| Thailand | 21,735 | 150,087 | 190,470 | 102,322 | 235,725 |
| Malaysia | 14,010 | 19,428 | 45,223 | 89,844 | 129,332 |
| Viet Nam | 115,447 | 96,146 | 148,825 | 116,296 | 108,058 |
| Philippines | 7,206 | 2,646 | 1,408 | 2,395 | 13,984 |
| Indonesia | 4,162 | 4,168 | 6,312 | 8,101 | 11,325 |
| Laos | 361 | 884 | 1,233 | 2,068 | 582 |
| Myanmar | 39 | 2 | 79 | 83 | 675 |
| Brunei | 30 | 26 | 7 | 19 | 197 |

Source: ITC

# CAMBODIA'S IMPORT FROM ASEAN

US Dollar Thousand

| | 2009 | 2010 | 2011 | 2012 | 2013 |
|---|---|---|---|---|---|
| Total Import | 1,454,609 | 1,684,015 | 2,236,120 | 2,506,535 | 2,832,285 |
| Thailand | 465,233 | 690,723 | 726,477 | 902,258 | 1,095,533 |
| Viet Nam | 493,812 | 487,291 | 882,921 | 937,013 | 987,555 |
| Singapore | 209,029 | 155,705 | 238,058 | 258,430 | 348,518 |
| Indonesia | 145,727 | 175,303 | 169,283 | 215,673 | 246,994 |
| Malaysia | 132,214 | 165,548 | 209,723 | 175,416 | 140,665 |
| Philippines | 7,049 | 7,364 | 8,157 | 13,360 | 7,389 |
| Laos | 525 | 1,498 | 926 | 4,262 | 5,368 |
| Myanmar | 61 | 52 | 132 | 114 | 263 |
| Brunei | 959 | 531 | 443 | 9 | 0 |

Source: ITC

# CAMBODIA'S TOTAL TRADE WITH ASEAN+1 FTA

US Dollar Thousand

| | 2009 | 2010 | 2011 | 2012 | 2013 |
|---|---|---|---|---|---|
| ASEAN+1 FTA | 3,537,017 | 3,808,018 | 4,460,135 | 5,604,198 | 6,707,721 |
| China | 898,845 | 1,251,289 | 1,893,530 | 2,345,101 | 3,284,836 |
| Hong Kong | 2,134,039 | 1,939,750 | 1,678,373 | 2,178,079 | 2,256,753 |
| Japan | 198,798 | 246,214 | 401,802 | 422,155 | 509,919 |
| South Korea | 218,721 | 272,616 | 347,446 | 482,599 | 469,585 |
| Australia | 46,284 | 37,602 | 48,200 | 61,186 | 80,255 |
| India | 40,330 | 60,547 | 86,249 | 112,113 | 100,678 |
| New Zealand | 0 | O | 4,535 | 2,965 | 5,695 |

Source: ITC

# CAMBODIA’S EXPORT
# TO ASEAN+1 FTA

**US Dollar Thousand**

| | 2009 | 2010 | 2011 | 2012 | 2013 |
|---|---|---|---|---|---|
| Total Export | 1,777,196 | 1,595,362 | 1,600,144 | 2,190,278 | 2,371,957 |
| Hong Kong | 1,649,384 | 1,386,447 | 1,198,995 | 1,682,659 | 1,587,785 |
| China | 16,383 | 65,008 | 154,598 | 182,896 | 280,545 |
| Japan | 79,855 | 89,557 | 153,379 | 199,168 | 334,407 |
| South Korea | 9,359 | 24,486 | 46,390 | 78,162 | 98,299 |
| Australia | 17,387 | 21,831 | 32,272 | 36,858 | 60,080 |
| India | 4,828 | 8,033 | 12,221 | 8,907 | 7,389 |
| New Zealand | 0 | 0 | 2,289 | 1,628 | 3,452 |

Source: ITC



## CAMBODIA’S IMPORT
## FROM ASEAN+1 FTA

**US Dollar Thousand**

| | 2009 | 2010 | 2011 | 2012 | 2013 |
|---|---|---|---|---|---|
| Total Import | 1,759,821 | 2,212,656 | 2,859,991 | 3,413,920 | 4,335,764 |
| China | 882,462 | 1,186,281 | 1,738,932 | 2,162,205 | 3,004,291 |
| Hong Kong | 484,655 | 553,303 | 479,378 | 495,420 | 668,968 |
| Japan | 118,943 | 156,657 | 248,423 | 222,987 | 175,512 |
| South Korea | 209,362 | 248,130 | 301,056 | 404,437 | 371,286 |
| India | 35,502 | 52,514 | 74,028 | 103,206 | 93,289 |
| Australia | 28,897 | 15,771 | 15,928 | 24,328 | 20,175 |
| New Zealand | 0 | 0 | 2,246 | 1,337 | 2,243 |

Source: ITC

# សារជាគន្លឹះស្ដីពីសហគមន៍សេដ្ឋកិច្ចអាស៊ាន





សារជាគន្លឹះស្ដីពីសហគមន៍សេដ្ឋកិច្ចអាស៊ាន



Key AEC Massages





សារជាគន្លឹះស្ដីពីសហគមន៍សេដ្ឋកិច្ចអាស៊ាន

# “ទីផ្សាររួម ទទួលផលប្រយោជន៍រួម ” “ពីដប់ប្រទេស ទៅជាសហគមន៍មួយ”

“SHARED MARKET, SHARED BENEFITS”. “FROM TEN to ONE”

- ជាមួយនឹងការកាត់បន្ថយរបាំងពាណិជ្ជកម្ម និង វិនិយោគ អ្នកវិនិយោគ អាចវិនិយោគដោយសេរី នៅក្នុងតំបន់, អាចទទួលបានមូលធនកាន់តែច្រើន និង អាចដឹកទំនិញឆ្លងកាត់ព្រំដែនដោយងាយស្រួល។

## “ច្បាប់កាន់តែសាមញ្ញ, ទីផ្សារកាន់តែច្រើន”

## “ការធ្វើពាណិជ្ជកម្មកាន់តែធំ”

- ពាណិជ្ជកម្មនៅក្នុងតំបន់ នឹងត្រូវបានសម្រួល តាមរយៈ ឯកសារពាណិជ្ជកម្ម និងគយ ព្រមទាំងច្បាប់ និងនីតិវិធី ប្រកបដោយភាពសាមញ្ញ សុខដុម និងការកែលម្អ

https://www.facebook.com/moc.gov.kh

## "អាស៊ាន: ជាតំបន់សម្រាប់ការវិនិយោគរបស់លោកអ្នក"
## "ជាដៃគូអាជីវកម្ម"

- បរិយាកាសអាជីវកម្មកាន់តែល្អ ធ្វើឲ្យវិនិយោគិនដែលមិនទាន់ធ្វើអាជីវកម្មនៅក្នុងអាស៊ាន មកធ្វើអាជីវកម្មក្នុងអាស៊ាន, ផ្តល់ជំនឿទុកចិត្តប្រសើរជាងមុនសម្រាប់អ្នកវិនិយោគបច្ចុប្បន្ន ក្នុងអាស៊ាន និងបង្កើនការវិនិយោគទៅវិញទៅមកក្នុងអាស៊ាន ។

# "ធ្វើមូលធនឲ្យធ្វើការជូនអស់លោកអ្នក"
# "ពង្រីកការទទួលបានហិរញ្ញវត្ថុ"

- វិស័យហិរញ្ញវត្ថុអាស៊ានកាន់តែរឹងមាំ បានជួយជំរុញឲ្យមានអន្តរកម្មហិរញ្ញវត្ថុខ្លាំងឡើង, សមត្ថភាព និងការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុកាន់តែរឹងមាំ ដើម្បីជួយគាំទ្រការរីកលូតលាស់ដល់កំណើនសេដ្ឋកិច្ច និងបង្កើនកិច្ចសហប្រតិបត្តិការរិតតែប្រសើរថែមទៀត ដើម្បីកាត់បន្ថយភាពគ្រោះថ្នាក់ពីវិបត្តិសេដ្ឋកិច្ចខាងក្រៅ និងការប្រែប្រួលទីផ្សារ។

# “អ្នកជំនាញអាស៊ានកំពុងធ្វើការបម្លាស់ទី”
# “ប្រជាជនល្អបំផុត និងការអនុវត្តប្រសើរបំផុត”

- អ្នកជំនាញច្រើនប្រភេទ នៅក្នុងប្រទេសសមាជិកអាស៊ានទាំង១០ ដែលអាចធ្វើការបម្លាស់ទីពីប្រទេសមួយទៅប្រទេសមួយ នឹងធ្វើឲ្យនិយោជកមានការងាយស្រួលក្នុងការពង្រីកអាជីវកម្មរបស់ខ្លួននៅក្នុងតំបន់ៗ ”

# តើយើងនឹងធ្វើអ្វីទៀត?

# សហគមន៍របស់យើង ដំណើររបស់យើង

- អាស៊ានបានសន្យាបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំ២០១៥ ហើយការងារជាច្រើនត្រូវបានសម្រេច។ ទោះបី មានបញ្ហាប្រឈមនានានៅពេលខាងមុខ ការប្តេជ្ញារបស់អាស៊ាននៅតែរឹងមាំ និងមិនថយក្រោយ។
- នៅក្នុងឆ្នាំ២០១៣ ប្រមុខរដ្ឋ/រដ្ឋាភិបាល បានសន្យាបង្កើត "ចក្ខុវិស័យក្រោយឆ្នាំ២០១៥" ("Post-2015 Vision")។ គោលដៅរបស់ប្រមុខដឹកនាំ គឺត្រូវធ្វើឲ្យសម្រេចនូវសហគមន៍មួយដែល "មាននយោបាយស្អិតរមួតនឹងគ្នា មានសមាហរណកម្មសេដ្ឋកិច្ចនឹងគ្នា ជាសង្គមទទួលខុសត្រូវរួមគ្នា ហើយជាសហគមន៍អាស៊ានមួយដែលផ្តោតការយកចិត្តទុកដាក់លើប្រជាជនយ៉ាងពិតប្រាកដ យកប្រជាជនជាស្នូល និងជាសហគមន៍ដែលយកច្បាប់ជាមូលដ្ឋាន"
- ប្រជាជនអាស៊ានរបស់យើង គឺជាកត្តាដ៏សំខាន់បំផុតនៅលើដំណើររបស់យើង ហើយនេះគឺជាឱកាសមាសសម្រាប់ការរីកចំរើនរបស់អាជីវកម្មក្នុងតំបន់។

**ឆ្នាំ ២០១៥ : គ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ**

**យើងត្រូវចាប់យកឱកាសមាស !**

**យើងត្រូវចូលរួមទាំងអស់គ្នា !**



https://www.facebook.com/moc.gov.kh

លោកអ្នកអាចទាញយកបទបង្ហាញនេះតាមរយៈ

**www.facebook.com/moc.gov.kh**

# សូមអរគុណ!